ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៣៥៣ ឧវបន . ចល . ព្រក

# សេចក្តីប្រកាសព័ត៌មានផ្ទៃក្នុង
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់សេវាអ៊ីនធឺណិតកែសម្រួលថ្មី (Upgraded) នៅទីស្តីការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ដើម្បីរួមចំណែកលើការងារជំរុញនិងគាំទ្រសេដ្ឋកិច្ចឌីជីថល និងយោងតាមការចង្អុលបង្ហាញពី **ឯកឧត្តមរដ្ឋមន្ត្រី** ក្នុងការពង្រឹងការប្រើប្រាស់សេវាអ៊ីនធឺណិតនៅទីស្តីការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (**ឧ.វ.ប.ន.**) អង្គភាពបរិវត្តកម្មឌីជីថល និងខុទ្ទកាល័យ មានសេចក្តីសោមនស្សរីករាយគោរពជម្រាបជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកទាំងអស់នៃក្រសួង **ឧ.វ.ប.ន.** អំពីការដាក់ឱ្យដំណើរការប្រព័ន្ធសេវាអ៊ីនធឺណិតកែសម្រួលថ្មី ដែលនឹងគ្រោងដាក់ឱ្យប្រើប្រាស់នៅក្នុងសប្តាហ៍ទី ៤ នៃខែធ្នូ ឆ្នាំ២០២៣ នេះ។

ប្រព័ន្ធសេវាអ៊ីនធឺណិតកែសម្រួលថ្មីនេះនឹងមានល្បឿនលឿនកម្រិត **១០ ជីហ្គាប៊ីតក្នុងមួយវិនាទី** (10 Gbps) និងមានលក្ខណៈស្ថេរភាពនិងដែនសេវាខ្លាំង។ ប្រព័ន្ធនេះនឹងអាចជួយសម្រួលការងាររបស់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិករបស់ក្រសួង **ឧ.វ.ប.ន.** កាន់តែប្រសើរ ព្រមទាំងសម្រួលការស្នើសុំសេវាសាធារណៈនានានៅក្រោមក្រសួង **ឧ.វ.ប.ន.** កាន់តែប្រសើរ, ងាយស្រួល, កាន់តែមានប្រសិទ្ធភាព, ចំណាយពេលតិច, និងគួរឱ្យទុកចិត្តបានតាមប្រព័ន្ធឌីជីថល។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា** មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការក្នុងការប្រើប្រាស់ប្រព័ន្ធសេវាអ៊ីនធឺណិតកែសម្រួលថ្មីនេះឱ្យបានតាមធម្មានុរូប ដើម្បីបង្កើនប្រសិទ្ធភាពការងារដោយអនុលោមតាមសេចក្តីណែនាំបច្ចេកទេសរបស់អង្គភាពបរិវត្តកម្មឌីជីថលនៃក្រសួង **ឧ.វ.ប.ន.**

ថ្ងៃសុក្រ ១០រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣

**ព័ត៌មានបន្ថែម សូមទាក់ទង៖**


- មន្ត្រីបច្ចេកទេសសេវាអ៊ីនធឺណិត

១. លោក **ថន សុចិត្រា**
ទូរសព្ទ៖ 088 558 5543
២. លោក **ហ៊ឹម ទីវន្តិ**
ទូរសព្ទ៖ 096 414 8460